**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០៣៧៤ ព.ណ.គ.ក..

ថ្ងៃ ពុធ ១រោច ខែផល្គុន ឆ្នាំម្សាញ់ ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០២៦

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជនទូទៅឱ្យបានជ្រាបថា ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន នឹងបន្តរៀបចំ «ពិព័រណ៍កម្ពុជា លើកទី១០ ឆ្នាំ២០២៦» ពីថ្ងៃទី៣-៤ ខែឧសភា ឆ្នាំ២០២៦ នៅសួនឧទ្យានយ៉ូយ៉ូហ្គិ ទីក្រុងតូក្យូ ប្រទេសជប៉ុន។ ព្រឹត្តិការណ៍ពិព័រណ៍នេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងលើកស្ទួយសិល្បៈ វប្បធម៌ ទេសចរណ៍ ព្រមទាំងជំរុញផលិតផលសក្តានុពល និងម្ហូបអាហារខ្មែរទៅកាន់ទីផ្សារអន្តរជាតិ។ គណៈកម្មការរៀបចំបានផ្តល់ស្តង់ចំនួនពីរជូនក្រសួងពាណិជ្ជកម្ម ដើម្បីផ្តល់ជូនក្រុមហ៊ុន និងសហគ្រាសកម្ពុជា ក្នុងការនាំយកផលិតផលនិងសេវាកម្មទៅដាក់តាំងបង្ហាញ ផ្សព្វផ្សាយ និងស្វែងរកដៃគូពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិនាឱកាសព្រឹត្តិការណ៍ខាងលើ។

ក្រសួងពាណិជ្ជកម្ម ក្នុងនាមអ្នកសម្របសម្រួល សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមធ្វើការទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ +៨៥៥ ៨៩ ៩១១ ១០១ / +៨៥៥ ៨៧ ៧៥៥ ៥៥១ ឬតាមរយៈប្រព័ន្ធទូរស័ព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ១២៦៦ ឬអ៊ីម៉ែល៖ san.phirun@moc.gov.kh / tong.rita@moc.gov.kh។

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ

https://go.gov.kh/moc/klwdu8
GO.gov.KH

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°0.744MOC.D/EA

Phnom Penh, 4 March 2026

## ANNOUNCEMENT

The Ministry of Commerce of the Kingdom of Cambodia has the honor to inform traders, producers, investors, and the public that the Royal Embassy of the Kingdom of Cambodia to Japan will organize "The 10th Cambodia Festival 2026", from 3-4 May 2026 at Yoyogi Park, Tokyo, Japan. This event aims to promote Khmer arts and culture, tourism, and potential Cambodian products and cuisine to the international market. The organizing committee has allocated two booths to the Ministry of Commerce for distribution to Cambodian companies wishing to showcase their products and services and to build networks with potential international buyers during the event.

In this regard, the Ministry of Commerce, as a facilitator, would like to cordially invite interested Cambodian traders, producers, investors, and the public to kindly register with the Department of Exhibition Affairs, General Directorate Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, or officials in charge via:

Tel: +855 89 911 101 / +855 87 755 551

MOC Call Center: 1266

E-mail: san.phirun@moc.gov.kh / tong.rita@moc.gov.kh.

scan to register

https://go.gov.kh/moc/klwdu8

GO.gov.KH

THANK YOU!

Ministry of Commerce, Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

Phone/Facsimile: (855) 23 866 469